ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាដើម្បីចូលបម្រើការងារ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹង ដល់សាធារណៈជនឱ្យបានជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាសរុបចំនួន **១១ រូប** មកបម្រើការងារពេញម៉ោងនៅមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងមុខតំណែងដូចខាងក្រោម

- អ្នកអភិវឌ្ឍកម្មវិធីផ្នែកខាងក្រោយ (Backend Developer) ចំនួន ០២ រូប
- វិស្វករផ្នែកអភិវឌ្ឍកម្មវិធី (Full Stack Developer) ចំនួន ០១ រូប
- អ្នកអភិវឌ្ឍកម្មវិធីទូរសព្ទ (Mobile Developer) ចំនួន ០២ រូប
- បុគ្គលិកទំនាក់ទំនងសាធារណៈ (Public Relation Officer) ចំនួន ០២ រូប
- បុគ្គលិកគាំទ្រប្រតិបត្តិការ (Operation Officer) ចំនួន ០២ រូប
- បុគ្គលិករចនាក្រាហ្វិក និង វីដេអូ (Graphic Designer and Video Editor) ចំនួន ០១ រូប
- បុគ្គលិកស្រាវជ្រាវគោលនយោបាយ (Policy Researcher) ចំនួន ០១ រូប

បេក្ខជនដែលត្រូវបានជ្រើសរើស នឹងទទួលបានប្រាក់បៀវត្សមូលដ្ឋានសមរម្យទៅតាមតួនាទីភារកិច្ច, បទពិសោធន៍ និង គុណវុឌ្ឍិ ស្របតាមលក្ខខណ្ឌកំណត់ជាធរមាន។

បេក្ខជន បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមចូលបំពេញបែបបទ និង ដាក់ពាក្យតាមរយៈគេហទំព័រ https://career.techostartup.center ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈអាសយដ្ឋានអេឡិចត្រូនិក៖ haksrun.ly@techostartup.center ។

បេក្ខជនដែលជាប់ដំណាក់កាលសម្រាំងជ្រើសរើស (Shortlist) នឹងត្រូវអញ្ជើញមកសម្ភាសផ្ទាល់មាត់។

ការទទួលពាក្យចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះរហូតដល់**ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០២៤ វេលាម៉ោង ១៧:០០ នាទី**។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# លក្ខខណ្ឌយោង
# ស្ដីពី
# ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាចំនួន ១១ រូប
# ដើម្បីចូលរួមបម្រើការងារនៅ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ១. អ្នកអភិវឌ្ឍកម្មវិធីផ្នែកខាងក្រោយ (Backend Developer) ចំនួន ០២ រូប

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- អភិវឌ្ឍ បង្កើត រចនា ថ្នាលបច្ចេកវិទ្យាឌីជីថល របស់អង្គភាព
- ទទួលខុសត្រូវលើការរៀបចំ និង គ្រប់គ្រងប្រព័ន្ធថ្នាលឌីជីថលរបស់គម្រោង និង អង្គភាព
- វាយតម្លៃ និង ត្រួតពិនិត្យតាមដានថ្នាលបច្ចេកវិទ្យាឌីជីថលផ្សេងៗ និង ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ
- ទំនាក់ទំនង និង សម្របសម្រួលការងារ ក្រុមការងារបច្ចេកទេស របស់អង្គភាព គម្រោង ឬ ភ្នាក់ងារពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍ និង ស្រាវជ្រាវ
- ពិនិត្យ រៀបចំ សម្របសម្រួល និង សហការការងារជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំកិច្ចប្រជុំបច្ចេកទេសនានា
- ចូលរួមក្នុងការរចនាថ្នាលឌីជីថលដោយប្រើប្រាស់វិធីសាស្ត្រ Agile ក្នុងការគ្រប់គ្រងគម្រោង, ការធ្វើតេស្ត, ការដាក់ឱ្យសាកល្បង និង ការដាក់ឱ្យអនុវត្តជាក់ស្ដែង
- រៀបចំ និង ប្រើប្រាស់បច្ចេកវិទ្យា Modern Web Services Architecutre ដើម្បីធ្វើសន្ទានកម្មជាមួយសេវា ឬ ថ្នាលឌីជីថលផ្សេងៗ
- រៀបចំ និង បណ្ដុះបណ្ដាលបុគ្គលិក អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល និង មន្ត្រីជំនាញពាក់ព័ន្ធតាមការចាំបាច់
- អនុវត្តភារកិច្ចការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ ។

*បេក្ខជន ត្រូវមានគុណវុឌ្ឍិទូទៅដូចខាងក្រោម៖*

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រឡើងទៅលើជំនាញបច្ចេកវិទ្យា វិទ្យាសាស្ត្រកុំព្យូទ័រ ឬ សញ្ញាបត្រជំនាញប្រហាក់ប្រហែល
- មានបទពិសោធន៍ទាក់ទងនឹងផ្នែកអភិវឌ្ឍប្រព័ន្ធ និង សរសេរកម្មវិធី យ៉ាងតិច ០៣ ឆ្នាំ
- មានបទពិសោធន៍ទាក់ទងនឹង RESTful APII, Websocket, NodeJS, FastAPI, mongoDB, ProgressSQL

- មានបទពិសោធន៍សម្របសម្រួលការងារ និង ទំនាក់ទំនងជាមួយវិស័យរដ្ឋ វិស័យឯកជន ឬ ដៃគូអភិវឌ្ឍន៍
- មានចំណេះដឹងភាសាខ្មែរ និង ភាសាអង់គ្លេសច្បាស់លាស់ អាចនិយាយ សរសេរ និង ប្រើប្រាស់ជាផ្លូវការបាន
- មានគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិត សមត្ថភាពបំពេញការងារដោយឯករាជ្យ និង ការងារជាក្រុមបានល្អ រួមទាំងមានជំនាញក្នុងការប្រាស្រ័យទំនាក់ទំនងល្អប្រសើរ
- មានអត្តចរិតស្លូតបូត ស្មោះត្រង់ អត់ធ្មត់ ឧស្សាហ៍ព្យាយាម និង យកចិត្តទុកដាក់បំពេញការងារ
- មានអាកប្បកិរិយាល្អ គោរពក្រមសីលធម៌វិជ្ជាជីវៈ និង ពុំមានជាប់ទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិម
- មានឆន្ទៈខ្ពស់ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាង និង អភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និង សង្គមឌីជីថល
- មានចំណេះដឹងពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ច និង សង្គមឌីជីថល។

**២. វិស្វករផ្នែកអភិវឌ្ឍកម្មវិធី** ( Full Stack Developer ) **ចំនួន ០១ រូប**

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- រៀបចំ និង អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ទៅតាមតម្រូវការ និង ការចាំបាច់របស់គម្រោង និង អង្គភាព
- ចូលរួមដំណើរអភិវឌ្ឍប្រព័ន្ធ និង សហការជាមួយភ្នាក់ងារពាក់ព័ន្ធនានា
- រៀបចំធ្វើការសាកល្បង និង លំហែទាំទៅលើថ្នាលឌីជីថល
- ធានាថារាល់មុខងាររបស់ថ្នាលឌីជីថលដែលដាក់ឱ្យដំណើរការ មានប្រសិទ្ធិភាពមុខងារដែលអាចដំណើរការទៅយ៉ាងរលូន
- រៀបចំចងក្រងឯកសារនៃការអភិវឌ្ឍប្រព័ន្ធនីមួយៗ និង រៀបចំសៀវភៅណែនាំការប្រើប្រាស់
- ធានាថាប្រព័ន្ធ ឬ ថ្នាលបច្ចេកវិទ្យាត្រូវបានអភិវឌ្ឍប្រកបដោយសុវត្ថិភាព និង សមស្របទៅតាមគោលការណ៍នានា
- ទំនាក់ទំនង និង សម្របសម្រួលការងារ ក្រុមការងារបច្ចេកទេស របស់អង្គភាព គម្រោង ឬ ភ្នាក់ងារពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍ និង ស្រាវជ្រាវ
- រៀបចំ និង បណ្តុះបណ្តាលបុគ្គលិក អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល និង មន្ត្រីជំនាញពាក់ព័ន្ធតាមការចាំបាច់
- អនុវត្តភារកិច្ចការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ ។

*បេក្ខជន ត្រូវមានគុណវុឌ្ឍិទូទៅដូចខាងក្រោម៖*

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រឡើងទៅលើជំនាញបច្ចេកវិទ្យា វិទ្យាសាស្ត្រកុំព្យូទ័រ ឬ សញ្ញាបត្រជំនាញប្រហាក់ប្រហែល
- មានបទពិសោធន៍ទាក់ទងនឹងផ្នែកអភិវឌ្ឍកម្មវិធីយ៉ាងតិច ០២ ឆ្នាំ
- មានបទពិសោធន៍ទាក់ទងភាសាកុំព្យូទ័រ ដូចជា Java, Python, NodeJs, C#, Next.Js

- មានបទពិសោធន៍សម្របសម្រួលការងារ និង ទំនាក់ទំនងជាមួយវិស័យរដ្ឋ វិស័យឯកជន ឬ ដៃគូអភិវឌ្ឍន៍
- មានចំណេះដឹងភាសាខ្មែរ និង ភាសាអង់គ្លេសច្បាស់លាស់ អាចនិយាយ សរសេរ និង ប្រើប្រាស់ជាផ្លូវការបាន
- មានផ្នត់គំនិតលូតលាស់ក្នុងការបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និង បង្ហាញពីឆន្ទៈខ្ពស់ក្នុងការរៀនសូត្រចំណេះដឹងថ្មី
- មានគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិត សមត្ថភាពបំពេញការងារដោយឯករាជ្យ និង ការងារជាក្រុមបានល្អ រួមទាំងមានជំនាញក្នុងការប្រាស្រ័យទំនាក់ទំនងល្អប្រសើរ
- មានអត្តចរិតស្លូតបូត ស្មោះត្រង់ អត់ធ្មត់ ឧស្សាហ៍ព្យាយាម និង យកចិត្តទុកដាក់បំពេញការងារ
- មានអាកប្បកិរិយាល្អ គោរពក្រមសីលធម៌វិជ្ជាជីវៈ និង ពុំមានជាប់ទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិម
- មានឆន្ទៈខ្ពស់ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាង និង អភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និង សង្គមឌីជីថល
- មានចំណេះដឹងពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ច និង សង្គមឌីជីថល។

## ៣. អ្នកអភិវឌ្ឍកម្មវិធីទូរសព្ទ ( Mobile Developer ) ចំនួន ០២ រូប

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- អភិវឌ្ឍកម្មវិធីទូរសព្ទដៃ និង Tablet សម្រាប់គម្រោង និង អង្គភាព
- រៀបចំរចនា និង គូស UX/UI សម្រាប់កម្មវិធីទូរស័ព្ទនានារបស់អង្គភាព
- ទំនាក់ទំនង និង សម្របសម្រួលការងារផ្ទៃក្នុងរបស់អង្គភាព គម្រោង ឬ ភ្នាក់ងារពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍកម្មវិធី
- រៀបចំ និង អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាឌីជីថលតាមទូរស័ព្ទ ទៅតាមតម្រូវការ និង ការចាំបាច់របស់គម្រោង និងអង្គភាព
- ចូលរួមវគ្គបណ្តុះបណ្តាលតាមការចាត់បញ្ជូនរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និង ប្រចាំខែ ដោយផ្អែកទៅលើដំណើរការរបស់ប្រព័ន្ធ ទំហំនៃការចូលប្រើប្រាស់ លទ្ធផលតំហែទាំ និង ការគំរាមកំហែងផ្នែកប្រព័ន្ធសុវត្ថិភាពសម្រាប់ធ្វើការកែប្រែដើម្បីឱ្យមានភាពជឿនលឿន និង ប្រសើរឡើង
- រៀបចំ និង បណ្តុះបណ្តាលបុគ្គលិក អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល និង មន្ត្រីជំនាញពាក់ព័ន្ធតាមការចាំបាច់
- អនុវត្តភារកិច្ចការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ ។

*បេក្ខជន ត្រូវមានគុណវុឌ្ឍិទូទៅដូចខាងក្រោម៖*

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រឡើងទៅលើជំនាញបច្ចេកវិទ្យា វិទ្យាសាស្ត្រកុំព្យូទ័រ ឬ សញ្ញាបត្រជំនាញប្រហាក់ប្រហែល
- មានបទពិសោធន៍ទាក់ទងនឹងផ្នែកអ្នកអភិវឌ្ឍកម្មវិធីទូរសព្ទ យ៉ាងតិច ០២ ឆ្នាំ

- មានបទពិសោធន៍ទាក់ទងកុំព្យូទ័រ ដូចជា Java, Kotlin, OOP, Flutter / React-Native, AngularJS
- មានបទពិសោធន៍សម្របសម្រួលការងារ និង ទំនាក់ទំនងជាមួយវិស័យរដ្ឋ វិស័យឯកជន ឬ ដៃគូអភិវឌ្ឍន៍
- មានចំណេះដឹងភាសាខ្មែរ និង ភាសាអង់គ្លេសច្បាស់លាស់ អាចនិយាយ សរសេរ និង ប្រើប្រាស់ជាផ្លូវការបាន
- មានផ្នត់គំនិតលូតលាស់ក្នុងការបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និង បង្ហាញពីឆន្ទៈខ្ពស់ក្នុងការរៀនសូត្រចំណេះដឹងថ្មី
- មានគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិត សមត្ថភាពបំពេញការងារដោយឯករាជ្យ និង ការងារជាក្រុមបានល្អ រួមទាំងមានជំនាញក្នុងការប្រាស្រ័យទំនាក់ទំនងល្អប្រសើរ
- មានអត្តចរិតស្លូតបូត ស្មោះត្រង់ អត់ធ្មត់ ឧស្សាហ៍ព្យាយាម និង យកចិត្តទុកដាក់បំពេញការងារ
- មានអាកប្បកិរិយាល្អ គោរពក្រមសីលធម៌វិជ្ជាជីវៈ និង ពុំមានជាប់ទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិម
- មានឆន្ទៈខ្ពស់ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាង និង អភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និង សង្គមឌីជីថល
- មានចំណេះដឹងពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ច និង សង្គមឌីជីថល។

**៤. បុគ្គលិកទំនាក់ទំនងសាធារណៈ** ( Public Relation Officer ) **ចំនួន ០២ រូប**

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- ប្រមូលព័ត៌មាន ឬ ទិន្នន័យពាក់ព័ន្ធនឹងសកម្មភាពរៀបចំ ថ្នាលបច្ចេកវិទ្យាឌីជីថលដែលបានដាក់ឱ្យដំណើរការ ដើម្បីផលិតមាតិកា និង រៀបចំរចនាក្រាហ្វិក ផ្ទាំងរូបភាព វីដេអូ គំនូរជីវចល ឬ វីដេអូខ្លីៗ ដើម្បីផ្សព្វផ្សាយជាសាធារណៈ
- រៀបចំ និង គ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់គម្រោង
- ទំនាក់ទំនង និង សម្របសម្រួលការងារផ្ទៃក្នុងរបស់អង្គភាព គម្រោង ឬ ភ្នាក់ងារពាក់ព័ន្ធនានា
- ពិនិត្យ រៀបចំ សម្របសម្រួល និង សហការការងារជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទ ព្រឹត្តិការណ៍ចែករំលែកចំណេះដឹង និង យន្តការផ្សព្វផ្សាយនានា
- រៀបចំពិធិការ និង សម្របសម្រួលការងារទទួលភ្ញៀវជាតិ និង អន្តរជាតិរបស់អង្គភាព ដោយសហការជាមួយភ្នាក់ងារពាក់ព័ន្ធនានា
- រៀបចំ និង បណ្តុះបណ្តាលបុគ្គលិក អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល និង មន្ត្រីជំនាញពាក់ព័ន្ធតាមការចាំបាច់
- អនុវត្តភារកិច្ចការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ ។

*បេក្ខជន ត្រូវមានគុណវុឌ្ឍិទូទៅដូចខាងក្រោម៖*

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រឡើងទៅលើជំនាញរដ្ឋបាលសាធារណៈ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ទំនាក់ទំនងអន្តរជាតិ ឬ សញ្ញាបត្រជំនាញប្រហាក់ប្រហែល

- មានបទពិសោធន៍ទាក់ទងនឹងផ្នែកទំនាក់ទំនងសាធារណៈយ៉ាងតិច ០១ ឆ្នាំ
- មានបទពិសោធន៍ទាក់ទងនឹងការផលិតមាតិកា វីដេអូ
- មានចំណេះដឹងប្រើប្រាស់កម្មវិធី ការិយាល័យ ( Microsoft Office )
- មានបទពិសោធន៍សម្របសម្រួលការងារ និង ទំនាក់ទំនងជាមួយវិស័យរដ្ឋ វិស័យឯកជន ឬ ដៃគូអភិវឌ្ឍន៍
- មានចំណេះដឹងភាសាខ្មែរ និង ភាសាអង់គ្លេសច្បាស់លាស់ អាចនិយាយ សរសេរ និង ប្រើប្រាស់ជាផ្លូវការបាន
- មានបទពិសោធន៍សរសេរអត្ថបទខ្លីៗ សេចក្តីប្រកាសព័ត៌មាន ឬ អត្ថបទផ្លូវការនានា
- មានផ្នត់គំនិតល្អតលាស់ក្នុងការបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និង បង្ហាញពីឆន្ទៈខ្ពស់ក្នុងការរៀនសូត្រចំណេះដឹងថ្មី
- មានគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិត សមត្ថភាពបំពេញការងារដោយឯករាជ្យ និង ការងារជាក្រុមបានល្អ រួមទាំងមានជំនាញក្នុងការប្រាស្រ័យទំនាក់ទំនងល្អប្រសើរ
- មានអត្តចរិតស្លូតបូត ស្មោះត្រង់ អត់ធ្មត់ ឧស្សាហ៍ព្យាយាម និង យកចិត្តទុកដាក់បំពេញការងារ
- មានអាកប្បកិរិយាល្អ គោរពក្រមសីលធម៌វិជ្ជាជីវៈ និង ពុំមានជាប់ទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិម
- មានឆន្ទៈខ្ពស់ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាង និង អភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និង សង្គមឌីជីថល
- មានចំណេះដឹងពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ច និង សង្គមឌីជីថល។

**៥. បុគ្គលិកគាំទ្រប្រតិបត្តិការ** ( Operation Officer ) **ចំនួន ០២ រូប**

***ភារកិច្ច និង ការទទួលខុសត្រូវ៖***

- ប្រមូលព័ត៌មាន ឬ ទិន្នន័យពាក់ព័ន្ធនឹងសកម្មភាពរៀបចំ ថ្នាលបច្ចេកវិទ្យាឌីជីថលដែលបានដាក់ឱ្យដំណើរការ ដើម្បីគាំទ្រ និង ដោះស្រាយរាល់បញ្ហាដែលកើតមានឡើង
- រៀបចំ និង គ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់គម្រោង និង គ្រប់គ្រងលើការប្រតិបត្តិការនានា
- ទំនាក់ទំនង និង សម្របសម្រួលការងារផ្ទៃក្នុងរបស់អង្គភាព គម្រោង ឬ ភ្នាក់ងារពាក់ព័ន្ធនានា
- ពិនិត្យ រៀបចំ សម្របសម្រួល និង សហការការងារជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទ ព្រឹត្តិការណ៍ចែករំលែកចំណេះដឹង និង យន្តការផ្សព្វផ្សាយនានា
- រៀបចំពិធីការ និង សម្របសម្រួលការងារទទួលភ្ញៀវជាតិ និង អន្តរជាតិរបស់អង្គភាព ដោយសហការជាមួយភ្នាក់ងារពាក់ព័ន្ធនានា
- រៀបចំ និង បណ្តុះបណ្តាលបុគ្គលិក អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល និង មន្ត្រីជំនាញពាក់ព័ន្ធតាមការចាំបាច់
- អនុវត្តភារកិច្ចការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ ។

*បេក្ខជន ត្រូវមានគុណវុឌ្ឍិទូទៅដូចខាងក្រោម៖*

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រឡើងទៅលើជំនាញរដ្ឋបាលសាធារណៈ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ទំនាក់ទំនងអន្តរជាតិ ឬ សញ្ញាបត្រជំនាញប្រហាក់ប្រហែល
- មានបទពិសោធន៍យ៉ាងតិច ០១ ឆ្នាំ លើមុខងារគាំទ្រប្រតិបត្តិការ ឬ ប្រហាក់ប្រហែល
- មានចំណេះដឹងប្រើប្រាស់កម្មវិធី ការិយាល័យ ( Microsoft Office )
- មានបទពិសោធន៍សម្របសម្រួលការងារ និង ទំនាក់ទំនងជាមួយវិស័យរដ្ឋ វិស័យឯកជន ឬ ដៃគូអភិវឌ្ឍន៍
- មានចំណេះដឹងភាសាខ្មែរ និង ភាសាអង់គ្លេសច្បាស់លាស់ អាចនិយាយ សរសេរ និង ប្រើប្រាស់ជាផ្លូវការបាន
- មានផ្នត់គំនិតលូតលាស់ក្នុងការបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និង បង្ហាញពីឆន្ទៈខ្ពស់ក្នុងការរៀនសូត្រចំណេះដឹងថ្មី
- មានគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិត សមត្ថភាពបំពេញការងារដោយឯករាជ្យ និង ការងារជាក្រុមបានល្អ រួមទាំងមានជំនាញក្នុងការប្រាស្រ័យទំនាក់ទំនងល្អប្រសើរ
- មានអត្តចរិតស្លូតបូត ស្មោះត្រង់ អត់ធ្មត់ ឧស្សាហ៍ព្យាយាម និង យកចិត្តទុកដាក់បំពេញការងារ
- មានអាកប្បកិរិយាល្អ គោរពក្រមសីលធម៌វិជ្ជាជីវៈ និង ពុំមានជាប់ទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិម
- មានឆន្ទៈខ្ពស់ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាង និង អភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និង សង្គមឌីជីថល
- មានចំណេះដឹងពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ច និង សង្គមឌីជីថល។

**៦. បុគ្គលិករចនាក្រាហ្វិក និង វីដេអូ** ( Graphic Designer and Video Editor ) **ចំនួន ០១ រូប**

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- ប្រមូលព័ត៌មាន ឬ ទិន្នន័យពាក់ព័ន្ធនឹងសកម្មភាពរៀបចំ ថ្នាលបច្ចេកវិទ្យាឌីជីថលដែលបានដាក់ឱ្យដំណើរការ ដើម្បីផលិតមាតិកា និង រៀបចំរចនាក្រាហ្វិក ផ្ទាំងរូបភាព វីដេអូ គំនូរជីវចល ឬ វីដេអូខ្លីៗ ដើម្បីផ្សព្វផ្សាយជាសាធារណៈ
- រៀបចំផែនការ និង សកម្មនានា ទាក់ទងទៅនឹងការរចនា និង ផលិតមាតិកាដើម្បីផ្សព្វផ្សាយ
- ទំនាក់ទំនង និង សម្របសម្រួលការងារផ្ទៃក្នុងរបស់អង្គភាព គម្រោង ឬ ភ្នាក់ងារពាក់ព័ន្ធនានា
- ពិនិត្យ រៀបចំ សម្របសម្រួល និង សហការការងារជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទ ព្រឹត្តិការណ៍ចែករំលែកចំណេះដឹង និង យន្តការផ្សព្វផ្សាយនានា
- រៀបចំ និង បណ្តុះបណ្តាលបុគ្គលិក អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល និង មន្ត្រីជំនាញពាក់ព័ន្ធតាមការចាំបាច់
- អនុវត្តភារកិច្ចការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ ។

*បេក្ខជន ត្រូវមានគុណវុឌ្ឍិទូទៅដូចខាងក្រោម៖*

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រឡើងទៅលើជំនាញរដ្ឋបាលសាធារណៈ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ទំនាក់ទំនងអន្តរជាតិ ឬ សញ្ញាបត្រជំនាញប្រហាក់ប្រហែល
- មានបទពិសោធន៍ទាក់ទងនឹងផ្នែករចនាក្រាហ្វិក និង វីដេអូ យ៉ាងតិច ០១ ឆ្នាំ
- មានចំណេះដឹងប្រើប្រាស់កម្មវិធីកុំព្យូទ័រដូចជា Adobe Creative Suite (Photoshop, Illustrator, Premiere Pro) ឬ កម្មវិធីរចនាផ្សេងទៀត
- មានបទពិសោធន៍សម្របសម្រួលការងារ និង ទំនាក់ទំនងជាមួយវិស័យរដ្ឋ វិស័យឯកជន ឬ ដៃគូអភិវឌ្ឍន៍
- មានចំណេះដឹងភាសាខ្មែរ និង ភាសាអង់គ្លេសច្បាស់លាស់ អាចនិយាយ សរសេរ និង ប្រើប្រាស់ជាផ្លូវការបាន
- មានផ្នត់គំនិតល្អតលាស់ក្នុងការបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និង បង្ហាញពីឆន្ទៈខ្ពស់ក្នុងការរៀនសូត្រចំណេះដឹងថ្មី
- មានគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិត សមត្ថភាពបំពេញការងារដោយឯករាជ្យ និង ការងារជាក្រុមបានល្អ រួមទាំងមានជំនាញក្នុងការប្រាស្រ័យទំនាក់ទំនងល្អប្រសើរ
- មានអត្តចរិតស្លូតបូត ស្មោះត្រង់ អត់ធ្មត់ ឧស្សាហ៍ព្យាយាម និង យកចិត្តទុកដាក់បំពេញការងារ
- មានអាកប្បកិរិយាល្អ គោរពក្រមសីលធម៌វិជ្ជាជីវៈ និង ពុំមានជាប់ទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិម
- មានឆន្ទៈខ្ពស់ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាង និង អភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និង សង្គមឌីជីថល
- មានចំណេះដឹងពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ច និង សង្គមឌីជីថល។

**៧. មុខតំណែងស្រាវជ្រាវគោលនយោបាយ** (Policy Researcher) **ចំនួន ០១ រូប**

*ភារកិច្ច និង ការទទួលខុសត្រូវ៖*

- ចូលរួមក្នុងគម្រោងស្រាវជ្រាវ តាមរយៈការរចនាវិធីសាស្ត្រស្រាវជ្រាវ, ការប្រមូល និង ការវិភាគទិន្នន័យ និងការសរសេររបាយការណ៍បច្ចេកទេស
- រៀបចំឯកសារស្រាវជ្រាវ ប្រកបដោយវិជ្ជាជីវៈ និងសោភ័ណភាពសមរម្យសម្រាប់សាធារណជន
- បណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធតាមការស្នើសុំ
- បង្កើតទំនាក់ទំនងប្រកបដោយការគាំទ្រ និងទំនុកចិត្តជាមួយអ្នកពាក់ព័ន្ធ (ទាំងខាងក្នុង និងខាងក្រៅអង្គភាព) និង
- អនុវត្តភារកិច្ចដទៃទៀតតាមការប្រគល់ពីថ្នាក់ដឹកនាំ។

*បេក្ខជន ត្រូវមានគុណវុឌ្ឍិទូទៅដូចខាងក្រោម៖*

- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគោលនយោបាយសាធារណៈ វិទ្យាសាស្ត្រសង្គម ឬផ្នែកពាក់ព័ន្ធ
- មានបទពិសោធន៍ការងារក្នុងការស្រាវជ្រាវគោលនយោបាយ យ៉ាងតិច ១ ឆ្នាំ
- មានការយល់ដឹងច្បាស់លាស់ទាំងភាសាខ្មែរ និងភាសាអង់គ្លេស

- មានបទពិសោធន៍ និង ការយល់ដឹងពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល (ជាការប្រសើរ)
- មានសមត្ថភាពអនុវត្តការងារបានល្អ ជាពិសេសលើការងារជាក្រុម និងលម្អិត
- មានសមត្ថភាពបំពេញការងារដោយឯករាជ្យប្រកបដោយការទទួលខុសត្រូវ និងមានឆន្ទៈខ្ពស់ក្នុងការរៀនអ្វីថ្មី និង
- មានអាកប្បកិរិយាល្អ, គោរពក្រមសីលធម៌វិជ្ជាជីវៈ, ស្មោះត្រង់, អត់ធ្មត់, ឧស្សាហ៍ព្យាយាម, និងមានគំនិតនវានុវត្តន៍

*បេក្ខជនដែលជាប់ដំណាក់កាលសម្រាំងជ្រើសរើស (Shortlist) នឹងត្រូវអញ្ជើញមកសម្ភាសផ្ទាល់មាត់។*

*ការទទួលពាក្យចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០២៤ វេលាម៉ោង ១៧:០០ នាទី។*